### ៩.៣.១. ការឆ្លើយមតិយោបល់

| ល.រ | មតិយោបល់ | លេខទំព័រឆ្លើយតប |
|---|---|---|
| ១ | - **នៅក្នុងជំពូកពិពណ៌នាគម្រោង៖**<br>▪ នៅទំព័រទី៣ ចំណុច ៣.២ ទីតាំងគម្រោង ក្រុមហ៊ុនត្រូវបញ្ចូលបន្ថែមតារាងចំណុចនិយាមកានៃទីតាំងគម្រោង ទំហំផ្ទៃដីសរុប ទំហំផ្ទៃធ្វើអាជីវកម្ម ព្រំប្រទល់គម្រោង និងទំហំផ្ទៃសម្រាប់ធ្វើអាជីវកម្ម ដោយបញ្ចូលបន្ថែមផែនទីTopography និងផែនទីរដ្ឋបាល<br>▪ នៅទំព័រទី៦ ចំណុច ៣.៣.១ ផែនការអាជីវកម្ម ក្រុមហ៊ុនត្រូវពិនិត្យ កែសម្រួល និងផ្ទៀងផ្ទាត់ឡើងវិញនូវបរិមាណថ្មដែលត្រូវផលិតចំពោះការបកស្រាយ និងតារាង១<br>▪ នៅទំព័រទី១៣ ចំណុច ក. ការខួងដាក់រំសេវ និងការបំផ្ទុះ ក្រុមហ៊ុនត្រូវបញ្ជាក់បន្ថែមពីចំនួនរុន្ធដាក់រំសេវពេលបំផ្ទុះម្តងៗ ជម្រៅ ប្រភពរំសេវ និងបច្ចេកទេសបំផ្ទុះ<br>▪ នៅទំព័រទី១៥ ចំណុច ៣.៦.១ កម្លាំងពលកម្ម ក្រុមហ៊ុនត្រូវពិនិត្យ និងកែសម្រួលចំនួនប្រាក់ខែបុគ្គលិក-កម្មករឡើងវិញឱ្យបានត្រឹមត្រូវ<br>▪ នៅក្នុងជំពូកនេះ ម្ចាស់គម្រោងត្រូវបញ្ជាក់បន្ថែមពីទីតាំងស្តុកផេះថ្ម ចំនួនឡានទឹក ផែនការគ្រប់គ្រងសំណល់រឹង-រាវ | ក្រុមការងារឯកភាព និងបានកែសម្រួលរួចរាល់<br>- ទីតាំងគម្រោង កែរួចនៅទំព័រទី ៣ និងទី៤<br>- ៣.៣.១. ផែនការអាជីវកម្ម បានកែរួចនៅទំព័រទី៧<br>- ការខួងដាក់រំសេវ និងបំផ្ទុះ បានកែសម្រួលរួចនៅទំព័រទី ១១ ដល់ ១៣។<br>- កម្លាំងពលកម្ម សុំរក្សាទុកដដែល ព្រោះនេះ ជាអ្វីដែលក្រុមហ៊ុនវិនិយោគផ្តល់ព័ត៌មានឱ្យ។<br>- ផេះថ្ម នឹងបញ្ជាក់ក្នុងរបាយការណ៍ពេញលេញ<br>- ចំនួនឡានទឹក មានបញ្ជាក់នៅទំព័រទី១៨<br>- ផែនការគ្រប់គ្រងសំណល់ មានបញ្ជាក់នៅទំព័រទី ២២ ២៣ និង២៤។ |
| ២ | **ខ/ ទំហំ និងវិធីសាស្ត្រនៃការសិក្សា**<br>▪ នៅទំព័រទី២៨ ត្រង់ត្រេទី៥ ក្រុមហ៊ុនត្រូវកែសម្រួលខែនៃការសិក្សារៀបចំរបាយការណ៍ឱ្យបានត្រឹមត្រូវ។ | ក្រុមការងារឯកភាព និងបានកែសម្រួលរួចរាល់<br>- នៅទំព័រទី២៨ ត្រង់ត្រេទី៥ ក្រុមហ៊ុនត្រូវកែសម្រួលខែនៃការសិក្សារៀបចំរបាយការណ៍ឱ្យបានត្រឹមត្រូវ បានកែរួចនៅ |

| ល.រ | មតិយោបល់ | លេខទំព័រឆ្លើយតប |
|---|---|---|
| | ១. **ធនធានរូបសាស្ត្រ៖**<br>▪ **ដី៖** ត្រូវសិក្សាសណ្ឋានដី/ឋានលេខា ភូគព្ភសាស្ត្រ ចំណាត់ថ្នាក់ប្រភេទដី គុណភាពដីស្របតាមប្រភេទដីក្នុងតំបន់គម្រោង និងគុណភាពផេះថ្ម។<br>▪ **អាកាសធាតុ៖** ត្រូវសិក្សាទិន្នន័យយ៉ាងតិច ០៥ឆ្នាំចុងក្រោយ (ពីឆ្នាំ ២០១៤-២០១៨)។<br>▪ **គុណភាពខ្យល់៖** ត្រូវសិក្សាយ៉ាងតិច ០៣សំណាក ដែលសំណាកទី១ ស្ថិតនៅក្បែរភូមិកររបស់ប្រជាជននៅក្នុងភូមិព្រៃវាល សំណាកទី២ ស្ថិតនៅក្នុងទីតាំងគម្រោង និងសំណាកទី៣ ស្ថិតនៅក្បែរភូមិកររបស់ប្រជាជននៅក្នុងភូមិប្រាសាទ ចំពោះប៉ារ៉ាម៉ែត្រដែលត្រូវសិក្សាមានដូចជា CO $NO_2$ $SO_2$ Pb $O_3$ TSP PM10 និង PM2.5<br>▪ **សំឡេង និងរំញ័រ៖** ត្រូវសិក្សាយ៉ាងតិច ០៣សំណាក ដូចនឹងទីតាំងសិក្សាគុណភាពខ្យល់។<br>➢ ***<u>សម្គាល់៖</u>*** ចំពោះការសិក្សាគុណភាពខ្យល់ សំឡេង និងរំញ័រ ត្រូវសិក្សានៅពេលក្រុមហ៊ុនធ្វើអាជីវកម្ម (ពេលបំផ្ទុះថ្ម)។<br>▪ **ជលសាស្ត្រ និងប្រព័ន្ធផ្លូវទឹក៖** ក្រុមហ៊ុនត្រូវសិក្សាពីប្រព័ន្ធផ្លូវទឹកក្នុងតំបន់គម្រោង ដោយបញ្ជាក់ពីប្រភពទឹក ឈ្មោះអូរ និងទីតាំងឱ្យបាស់ ដោយភ្ជាប់បន្ថែមផែនទីប្រព័ន្ធផ្លូវឱ្យបានច្បាស់។<br>▪ **គុណភាពទឹកលើដី៖** ត្រូវសិក្សាយ៉ាងតិច ០២សំណាក ដែលសំណាកទី១ ទឹកទំនប់ស្ទាក់ទឹកស្ថិតនៅប៉ែកខាងលិចទីតាំងគម្រោង និងសំណាកទី២ ទឹកអូរស្ថិតនៅក្បែរទីតាំងគម្រោង ដោយធ្វើការប្រៀបធៀបជាមួយស្តង់ដារគុណភាពទឹក នៅតាមតំបន់ទឹកសាធារណៈ សម្រាប់អភិរក្សជីវៈចម្រុះក្នុង | ទំព័រទី ៣១។<br>- ដី បានកែសម្រួលរួចនៅទំព័រទី ៣៤ ដល់៤១។<br>- អាកាសធាតុ បានកែសម្រួលរួចរាល់នៅទំព័រទី ៤១។<br>- គុណភាពខ្យល់ បានកែរួចនៅទំព័រទី ៤២ និង៤៣។<br>- សំឡេង និងរំញ័រ បានកែសម្រួលរួចនៅទំព័រទី ៤៦ ដល់ ៥២<br>- ជលសាស្ត្រ និងប្រព័ន្ធផ្លូវទឹក ក្រុមការងារបានបញ្ជាក់រួចរាល់នៅទំព័រទី ៥២ ចំពោះផែនទីនឹងគូស នៅក្នុងរបាយការណ៍ពេញលេញ។<br>- គុណភាពទឹកលើដី ក្រុមការងារកែសម្រួលនៅទំព័រទី ៥៤ និង៥៥។<br>- គុណភាពទឹកក្រោមដី បានកែសម្រួលរួចនៅទំព័រទី ៤៦ និង ៤៧។<br>- ធនធានព្រៃឈើ៖ ត្រូវបញ្ជាក់ពីទំហំ និងវិធីសាស្ត្រនៃការសិក្សាឱ្យច្បាស់ ដោយត្រូវសិក្សាបន្ថែមពីផែនទីគម្របព្រៃឈើឆ្នាំ២០១០ ក្នុងតំបន់។<br>- ធនធានសត្វព្រៃ៖ ត្រូវបញ្ជាក់ពីទំហំ វិធីសាស្ត្រនៃការសិក្សាទៅតាមប្រភេទសត្វ និងគោលបំណងឱ្យច្បាស់ ដូចជាប្រភេទសត្វ ចរាចរណ៍ ជម្រក ប្រភពចំណី ជាដើម។<br>- ធនធានមច្ឆជាតិ ទាំងអស់នេះ ក្រុមការងារមានបញ្ជាក់រួចរាល់នៅទំព័រទី ៥៩ ដល់ ៧០។ |

| ល.រ | មតិយោបល់ | លេខទំព័រឆ្លើយតប |
|---|---|---|
| | ទឹក និងសម្រាប់ការពារសុខភាពសាធារណៈ (ឧបសម្ព័ន្ធ៤ និង៥ នៃអនុក្រឹត្យលេខ២៧ ស្តីពីការត្រួតពិនិត្យការបំពុលទឹក) របស់ក្រសួងបរិស្ថាន។<br>➢ តារាងទី១៥ ប៉ារ៉ាម៉ែត្រគុណភាពទឹកលើដី និងស្តង់ដារកំណត់ត្រង់កូឡោនស្តង់ដារទឹកសមុទ្រ ក្រុមហ៊ុនត្រូវកែសម្រួលទៅជា ស្តង់ដារសម្រាប់អាងស្តុកទឹក វិញ។<br>▪ **គុណភាពទឹកក្រោមដី៖** ត្រូវសិក្សាយ៉ាងតិច ០១សំណាក នៅក្នុងតំបន់គម្រោង ឬក្នុងភូមិរបស់ប្រជាពលរដ្ឋដែលរស់នៅក្បែរតំបន់គម្រោង។<br>២/ ***ធនធានជីវសាស្ត្រ*** (ត្រូវបន្ថែមការសិក្សាធនធានជីវសាស្ត្រនៅតំបន់ដែនជម្រកសត្វព្រៃស្រែពក)៖<br>▪ **ធនធានព្រៃឈើ៖** ត្រូវបញ្ជាក់ពីទំហំ និងវិធីសាស្ត្រនៃការសិក្សាឱ្យច្បាស់ ដោយត្រូវសិក្សាបន្ថែមពីផែនទីគម្របព្រៃឈើឆ្នាំ២០១០ ក្នុងតំបន់។<br>▪ **ធនធានសត្វព្រៃ៖** ត្រូវបញ្ជាក់ពីទំហំ វិធីសាស្ត្រនៃការសិក្សាទៅតាមប្រភេទសត្វ និងគោលបំណងឱ្យច្បាស់ ដូចជា ប្រភេទសត្វ ចរាចរណ៍ ជម្រកប្រភពចំណី ជាដើម។<br>▪ **ធនធានមច្ឆជាតិ៖** ត្រូវបញ្ជាក់ពីទំហំ វិធីសាស្ត្រ និងសិក្សាផ្ទាល់នៅទំនប់ស្នាក់ទឹក និងទឹកអូរនៅក្បែរទីតាំងគម្រោងឱ្យច្បាស់។<br>**៣/ ធនធានសេដ្ឋកិច្ច-សង្គម**<br>▪ ត្រូវជ្រើសរើសសំណាកដោយប្រើប្រាស់រូបមន្ត Yamane Taro 1967 ក្នុងកម្រិតលម្អៀង ៥% ពីក្នុងកាំរង្វង់សិក្សាយ ២គីឡូម៉ែត្រជុំវិញតំបន់គម្រោង។ | - ធនធានសេដ្ឋកិច្ច សង្គម បានកែសម្រួលរួចនៅទំព័រទី ៧២។<br>- ការចូលរួមពីសាធារណជន បានកែរួចនៅទំព័រទី ៧៦ និង ៧៧។<br>- ការវាយតម្លៃហេតុបប៉ះពាល់ និងវិធានការកាត់បន្ថយ បានកែសម្រួលរួចនៅទំព័រទី ៧៨ និង៧៩។<br>- ផែនការគ្រប់គ្រងបរិស្ថាន បានកែសម្រួលរួចនៅទំព័រទី៨០។ |

| ល.រ | មតិយោបល់ | លេខទំព័រឆ្លើយតប |
|---|---|---|
| | ▪ ត្រូវសិក្សាបន្ថែមនូវទិន្នន័យមានស្រាប់ (ទិន្នន័យភូមិ-ឃុំឆ្នាំ២០១៨)។ | |
| ៣ | **៤/ ការចូលរួមពីសាធារណជន**<br>▪ ត្រូវបញ្ជាក់វិធីសាស្ត្រឱ្យច្បាស់លាស់ និងដំណាក់កាលដំណាក់កាលនៃការពិគ្រោះយោបល់ជាមួយសាធារណជនឱ្យច្បាស់ ដោយត្រូវមាន ០៣ ដំណាក់កាលគឺ (១). ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋគោលដៅ (FGD) (២). ពិគ្រោះយោបល់ដោយផ្ទាល់ជាមួយអាជ្ញាធរមូលដ្ឋាន (ភូមិ-ឃុំ-ស្រុកពាក់ព័ន្ធ) (៣). ពិគ្រោះយោបល់ដោយផ្ទាល់ជាមួយមន្ទីរ និងស្ថាប័នពាក់ព័ន្ធ។<br>➢ ចំពោះមន្ទីរ-ស្ថាប័នដែលត្រូវពិគ្រោះយោបល់មានដូចជា៖ រដ្ឋបាលខេត្តកំពង់ស្ពឺ រដ្ឋបាលស្រុកសំរោងទង មន្ទីរបរិស្ថាន មន្ទីររ៉ែ និងថាមពល មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(ជំនាញជលផល និងព្រៃឈើ) មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរផែនការ មន្ទីរទេសចរណ៍ មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរផែនការ ស្នងការនគរបាលខេត្ត និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ។<br>➢ នៅទំព័រទី៧៣ ចំណុច ៤.២.៣ ដំណាក់កាលសិក្ខាសាលាពិគ្រោះយោបល់ស្តីពីលទ្ធផលនៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្រុមហ៊ុនត្រូវដកចំណុចនេះចេញ ពីព្រោះនេះជាលក្ខខណ្ឌការងារសម្រាប់សិក្សារៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង។<br>**៥/ ការវាយតម្លៃហេតុប៉ះពាល់ និងវិធានការកាត់បន្ថយ៖** ត្រូវបញ្ជាក់ពីទំហំ និងវិធីសាស្ត្រ | |

| ល.រ | មតិយោបល់ | លេខទំព័រឆ្លើយតប |
|---|---|---|
| | នៃការសិក្សាឱ្យច្បាស់។<br>**៦/ផែនការគ្រប់គ្រងបរិស្ថាន (EMP) ៖** ត្រូវបង្ហាញអំពីវិធីសាស្ត្រនៃការរៀបចំ(EMP) និងមូលនិធិបរិស្ថាននិងសង្គម។ | |
| | - គ/ ចំណុចបន្ថែម<br>- ក្របខណ្ឌច្បាប់៖ នៅទំព័រទី៧៦-៧៧ ក្រុមហ៊ុនត្រូវដកច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពី ការបង្ការ និងការពន្លត់អគ្គីភ័យ ច្បាប់ស្តិពីសហជីព ច្បាប់ស្តីពីសារពើពន្ធ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន ចេញ<br>- នៅទំព័រទី៨០ ក្រុមហ៊ុនត្រូវកែសម្រួលពាក្យ «ឯកសារពិគ្រោះ» ទៅជា «ឯកសារយោង» វិញ<br>- នៅទំព័រទី៨២ តារាង២៥ ផែនការសកម្មភាពនៃការសិក្សា ក្រុមហ៊ុនត្រូវពិនិត្យ និងកែសម្រួលឆ្នាំសិក្សាពី «២០១៨» ទៅជា «២០១៩» រយៈពេលពី ០៦ខែ ទៅជា ០៣ខែវិញ និងលុបពាក្យ «ក្រុមហ៊ុន កំពត អេឡិចទ្រីស៊ីធី សឹបផ្លាយ» ចេញ<br>- ត្រូវបញ្ជាក់បន្ថែមប្រភពទិន្នន័យរាល់តារាង និងផែនទីទាំងអស់<br>- ត្រូវដាក់រាល់ផែនទីទាំងអស់ជាក្រដាស A4 ឬ A3<br>- ត្រូវពិនិត្យ និងកែសម្រួលអក្ខរាវិរុទ្ធ និងឃ្លាមួយចំនួនឡើងវិញឱ្យបានត្រឹមត្រូវ។<br>- | គ.ចំណុចបន្ថែម<br>ក្រុមការងារឯកភាព និងបានកែសម្រួលរួចរាល់<br>- ក្របខណ្ឌច្បាប់ បានកែសម្រួលរួចនៅទំព័រទី ៨១ និង៨២។<br>- ឯកសារពិគ្រោះ ប្តូរមកជាឯកសារយោង នៅទំព័រទី៨៥។<br>- ផែនការសកម្មភាព ក្រុមការងារបានកែរួចនៅទំព័រទី៨៧។<br>- តារាង និងផែនទី ក្រុមការងារបានបញ្ជាក់រួចរាល់<br>- ផែនទី បានប្តូរពី A4 មកA3 រួចរាល់។<br>- ក្រុមការងារឯកភាព កែសម្រួលអក្ខរាវិរុទ្ធ និងឃ្លាមួយចំនួនឡើងវិញ រួចរាល់។ |